## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តរតនគិរី**

សំណុំរឿងព្រហ្មទណ្ឌ
លេខ : ១៨៧
ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២១

សាលក្រមព្រហ្មទណ្ឌ
លេខ : ២៧៩ "ក"
ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តរតនគិរី

បានបើកសវនាការជាសាធារណៈនៅថ្ងៃពុធ ៧កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនិងថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ ដោយមានសមាសភាពជំនុំជម្រះដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

ឯកឧត្តម [redacted] ប្រធានសាលាដំបូងខេត្តរតនគិរី

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តរតនគិរី

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តរតនគិរី

កញ្ញា [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ១៨៧ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] ដាវុធ ហៅ យួន ភេទប្រុស អាយុ ៤០ឆ្នាំ ជនជាតិខ្មែរ មុខរបរ រត់ម៉ូតូឌុប ទីកន្លែងកំណើត [redacted]ាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្នភូមិឃឺន ឃុំកក់ ស្រុកបរកែវ ខេត្តរតនគិរី ប្រពន្ធឈ្មោះ [redacted] ចាន់នឿន មានកូន ០១នាក់ ឪពុកឈ្មោះ [redacted] តារា (រស់) ម្តាយឈ្មោះ [redacted] ណយ (ស្លាប់) ទោសពីមុនគ្មាន ។(ក្នុងឃុំ)

២-ឈ្មោះ [redacted] រិទ្ធិ ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតនៅភូមិ [redacted]ាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្នភូមិឃឺន ឃុំកក់ ស្រុកបរកែវ ខេត្តរតនគិរី ឪពុកឈ្មោះ [redacted] ឈាងឡេង (រស់) ម្តាយឈ្មោះ [redacted] ផុន (រស់) ទោសពីមុនគ្មាន ។(ក្នុងឃុំ)

ជាប់ចោទពីបទ៖ រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិមួយ ឃុំឡាមិញ ស្រុកបរកែវ ខេត្តរតនគិរី កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិផ្តន្ទាទោសតាមមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**អង្គហេតុនៃរឿងមានដូចតទៅ ៖**

កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ នៅចំណុចភូមិមួយ ឃុំឡាមិញ ស្រុកបរកែវ ខេត្តរតនគិរី មានករណីរក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បង្កឡើងដោយជនសង្ស័យឈ្មោះ [redacted] ដាវុធ និងឈ្មោះ [redacted] រិទ្ធិ ដោយត្រូវបានកម្លាំងអធិការដ្ឋាននគរបាលស្រុកបរកែវបង្ក្រាបបាន តាមការរាយការណ៍ពីប្រជាពលរដ្ឋនៅមូលដ្ឋានថាមានករណីចែកចាយគ្រឿងញៀននៅទីតាំងខាងលើ ។ សមត្ថកិច្ចក៏បានដឹកនាំកម្លាំងចុះបង្ក្រាប និង

Scanned with CamScanner

តុលាការខេត្តរតនគិរី យល់ឃើញថា :

-យល់ឃើញថា: នៅតំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ជនជាប់ចោទឈ្មោះ [redacted] ជាវុធ បានឆ្លើយថា ខ្លួនបានធ្វើការលក់ដូរគ្រឿងញៀននៅក្នុងស្រុកបរកែវ អស់រយៈពេល ០២ ខែមកហើយ ការជួញដូរនេះពេលខ្លះ អ្នកទិញឲ្យខ្លួនយកថ្នាំទៅឲ្យ ពេលខ្លះគេមកយកដល់កន្លែង ។ ក្នុមួយថ្ងៃៗ ខ្លួនបានលក់គ្រឿងញៀនពី ០៥ ទៅ ០៦ កញ្ចប់តូចក្នុងតម្លៃ ៥០០០០ ទៅ ៦០០០០ រៀល។

-យល់ឃើញថា: តាមចម្លើយឈ្មោះ [redacted] ជាវុធ នៅតំណាក់កាលអយ្យការ បានឆ្លើយថា គ្រឿងញៀន ចំនួន ១៩ កញ្ចប់ ដែលសមត្ថកិច្ចបានដកហូតបាន ជាគ្រឿងញៀនរបស់ខ្លួននិងឈ្មោះ រិទ្ធិ បានចូលប្រាក់គ្នាទិញ ដើម្បីលក់បន្ត ។ នៅពេលសមត្ថកិច្ចសម្រុកចូលក្នុងឃ្លាំង ខ្លួនត្រូវបានសមត្ថកិច្ចឃាត់ខ្លួន រីឯឈ្មោះ រិទ្ធិ បានគេច ខ្លួនបាត់ ។

-យល់ឃើញថា: នៅចំពោះមុខចៅក្រមស៊ើបសួរកាលពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ ឈ្មោះ [redacted] ជាវុធ បានឆ្លើយថា ឈ្មោះ [redacted] រិទ្ធិ គឺជាមួយដែលធ្លាប់ប្រើខ្លួនឲ្យទិញបាយនិងម្ហូបតែប៉ុណ្ណោះ រីឯគ្រឿងញៀនដែលសមត្ថកិច្ចបានដកហូតគឺជារបស់ខ្លួនពាក់កណ្ដាល ពាក់កណ្ដាលទៀតជារបស់បង។

-យល់ឃើញថា: តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ជាវុធ និងឈ្មោះ [redacted] រិទ្ធិ ដែលជាចម្លើយ តទល់នៅចំពោះមុខចៅក្រមស៊ើបសួរ ឃើញថាឈ្មោះ [redacted] ជាវុធ មិនទទួលស្គាល់ចម្លើយដែលបានឆ្លើយនៅ សមត្ថកិច្ចកាលពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២១ ហើយឈ្មោះនេះបានបញ្ជាក់ថា ខ្លួនចេះតែឆ្លើយដោយខ្លាច សមត្ថកិច្ចឃាត់ខ្លួនបញ្ជូនមកតុលាការ ។ គ្រឿងញៀនដែលបានដកហូតនោះគឺទុកសម្រាប់ប្រើប្រាស់ មិនបាន លក់ដូរអ្វីទេ ដោយហេតុថា ខ្លួនបានទិញទុកសម្រាប់ប្រើរយៈពេលយូរ រីឯការឆ្លើយរបស់ខ្ញុំនៅចៅក្រមស៊ើបសួរ កាលពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ គ្រឿងញៀនដែលសមត្ថកិច្ចដកហូតបាននោះជារបស់ខ្លួនពាក់កណ្ដាល របស់បងពាក់កណ្ដាល គឺសម្ដៅទៅលើឈ្មោះ [redacted] រិទ្ធិ ជាបងប្រុស ។

-យល់ឃើញថា: តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] រិទ្ធិ នៅតំណាក់កាលសួរតទល់ចំពោះមុខចៅក្រម ស៊ើបសួរកាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ ជនជាប់ចោទបានឆ្លើយថា មិនបានជួញដូរគ្រឿងញៀនជាមួយ ឈ្មោះ [redacted] ជាវុធ នោះឡើយ ។

-យល់ឃើញថា: ចម្លើយជនជាប់ចោទឈ្មោះ [redacted] ជាវុធ គឺមានការផ្លាស់ប្ដូរគ្រប់តំណាក់កាល នៃការសួរ ចម្លើយទាំងអស់ ដែលមិនអាចដាក់បន្ទុកទៅលើឈ្មោះ [redacted] រិទ្ធិ ពីបទ រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុស ច្បាប់នូវសារធាតុញៀន ជាមួយគ្នានេះ ហើយក៏គ្មានមូលដ្ឋានដែលឲ្យតុលាការជឿថាឈ្មោះ [redacted] រិទ្ធិ មានថ្នាំញៀន ពាក់កណ្ដាលនោះដែរ ម៉្យាងវិញទៀតឈ្មោះ [redacted] រិទ្ធិ ក៏មិនទទួលស្គាល់ថ្នាំញៀន ដែលបានដកហូតពីឈ្មោះ [redacted] ជាវុធ ជារបស់ខ្លួនដែរ ។

-យល់ឃើញថា: នៅតំណាក់កាលសវនាការ ជនជាប់ចោទឈ្មោះ [redacted] រិទ្ធិ បានឆ្លើយមិនទទួលស្គាល់ថា បានលក់ដូរគ្រឿងញៀនជាមួយឈ្មោះ [redacted] ជាវុធ នោះទេ ប៉ុន្តែធ្លាប់បានប្រើប្រាស់គ្រឿងញៀនជាមួយឈ្មោះ [redacted] ជាវុធ ម៉្យាងវិញទៀតឈ្មោះ [redacted] ជាវុធ ជាអ្នកជួញដូរគ្រឿងញៀនចំនួន ១៩ កញ្ចប់ ដែលសមត្ថកិច្ចបាន ដកហូតបាន កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ ហើយឈ្មោះ [redacted] ជាវុធ ក៏ជាអ្នកប្រើប្រាស់គ្រឿងញៀននេះដែរ ។

Scanned with CamScanner

ឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] ជាវុធ រីឯ ឈ្មោះ [redacted] រិទ្ធិ បានរត់គេចខ្លួនបាត់ ។ នៅពេលឃាត់ខ្លួនឈ្មោះ [redacted] ជាវុធ សមត្ថកិច្ចបានធ្វើការដកហូត ម្សៅក្រាមសថ្លា (សង្ស័យសារធាតុញៀន) ចំនួន១៩កញ្ចប់ មានទម្ងន់ ៤,៨៤ក្រាម ( ទាំងសម្បកថង់ ) និងសម្ភារៈមួយចំនួនទៀត ។ លុះមកដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ ឈ្មោះ [redacted] រិទ្ធិ ត្រូវសមត្ថកិច្ចចាប់ខ្លួនបានបញ្ជូនមកចៅក្រមស៊ើបសួរ ចាត់ការតាមនីតិវិធីច្បាប់ ។

-បានឃើញរបាយការណ៍សំយោគរបស់អធិការដ្ឋាននគរបាលស្រុកបរកែវលេខៈ ៣២ ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២១ ។

-បានឃើញសេចក្ដីសន្និដ្ឋានបញ្ជូលឲ្យស៊ើបសួរ របស់តំណាងអយ្យការលេខៈ ៨៨ អ.យ/២១ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរ របស់តំណាងអយ្យការលេខៈ ១៥១ អ.យ/២១ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ ។

-បានឃើញដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះ របស់ចៅក្រមស៊ើបសួរលេខៈ ១៤៨ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ ២៦១ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] ជាវុធ បានឆ្លើយថាៈ ខ្លួនពិតជាបានធ្វើសកម្មភាព ជួញដូរគ្រឿងញៀន ប្រាកដមែន ដោយបានចូលប្រាក់ជាមួយឈ្មោះ [redacted] រិទ្ធិ ។ នៅពេលសមត្ថកិច្ចឃាត់ខ្លួនបានធ្វើការដកហូតគ្រឿងញៀន មានចំនួន ១៩ កញ្ចប់តូច ។ ពេលនេះរូបខ្ញុំដឹងកំហុសហើយ សូមលោក ចៅក្រម ដោះលែងរូបខ្ញុំបាននៅក្រៅឃុំ រូបខ្ញុំនឹងកែប្រែខ្លួន ។

-ជនជាប់ចោទឈ្មោះ [redacted] រិទ្ធិ បានឆ្លើយថាៈ ខ្លួនពិតជាបានលក់គ្រឿងញៀនពិតប្រាកដមែន ប៉ុន្តែមិនមានទ្រង់ទ្រាយធំទេ គឺបានលក់ឲ្យកម្មករចំនួន ០២នាក់ ដែលបានធ្វើការជាមួយខ្លួនប្រើនៅពេលធ្វើការងារមានភាពនឿយហត់។ ពេលដែលសមត្ថកិច្ចបានឃាត់ខ្លួន មិនបានធ្វើការដកហូតថ្នាំញៀនអ្វីពីខ្លួននោះឡើយ។

តំណាងអយ្យការបានសន្និដ្ឋានថាៈ ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ នាពេលសវនាការឃើញថាៈ ជនជាប់ចោទពិតជាបានរក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន សុំរក្សាដីកាសន្និដ្ឋានស្ថាពរលេខ ១៥១ អ.យ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ និងស្នើសុំឲ្យលោក ចៅក្រម ផ្ដន្ទាទោសជនល្មើសតាមច្បាប់ ។

មេធាវីការពារជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋានថាៈ កូនក្ដីនាងខ្ញុំពុំបាន ជួញដូរ រក្សាទុក និងប្រើប្រាស់នូវសារធាតុញៀនអ្វីឡើយ គឺជាជនរងគ្រោះ ប្រើប្រាស់គ្រឿងញៀនតែប៉ុណ្ណោះក្នុងពេលបំពេញការងារជាកម្មករ រីឯគ្រឿងញៀននៅសល់បានចែករំលែកឲ្យកម្មករចំនួន ០២នាក់ ប្រើប្រាស់ដូចគ្នា ហេតុនេះសុំផ្ដន្ទាទោសកូនក្ដីខ្ញុំ ពីបទ ប្រើប្រាស់ សុំឲ្យរួចផុតពីបទ រក្សាទុក ជួញដូរ ដើម្បីឲ្យកូនក្ដីនាងខ្ញុំមានឱកាសកែប្រែខ្លួន ។

ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ និងសំណូមពរ

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងអយ្យការ

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យពិចារណារបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌

ក្រោយពីបានពិនិត្យពិចារណាលើសំណុំរឿងទាំងមូលត្រឹមត្រូវតាមច្បាប់ហើយ

Scanned with CamScanner

-យល់ឃើញថាៈ ជនជាប់ចោទឈ្មោះ[redacted]រិទ្ធិ មិនមែនជាអ្នកជួញដូរគ្រឿងញៀនកាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ នោះឡើយ ប៉ុន្តែមានភស្តុតាងបញ្ជាក់ថា ជាអ្នកប្រើប្រាស់គ្រឿងញៀនដោយខុសច្បាប់នូវសារធាតុញៀន ។

-យល់ឃើញថាៈ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ដារ៉ុជ គឺជាបទល្មើស រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលច្បាប់បានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-យល់ឃើញថាៈ មានជាតុផ្សំបទល្មើស ភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ដារ៉ុជ ពីបទៈ រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងឈ្មោះ [redacted]រិទ្ធិ ពីបទៈ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។

-យល់ឃើញថាៈ អំពើរបស់ជនជាប់ចោទធ្វើឲ្យប៉ះពាល់ របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ ដែលច្បាប់បានការពារ ហើយត្រូវបានកំណត់ថាជាបទល្មើសព្រហ្មទណ្ឌត្រូវផ្តន្ទាទោស។

-យល់ឃើញថាៈ តំណាងអយ្យការដែលបានស្នើសុំរក្សាទុក សេចក្តីសន្និដ្ឋានស្ថាពរលេខ ១៥១ អ.យ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ ទុកជាបានការទាំងមូល ស្នើសុំឲ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់គប្បីតុលាការធ្វើការពិចារណាតាមច្បាប់។

-យល់ឃើញថាៈ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ សុំឲ្យតុលាការកែប្រែបទចោទពីបទៈ រក្សាទុក ជួញដូរ មកជាបទៈ ប្រើប្រាស់ ដើម្បីបានដោះលែងកូនក្តីខ្លួននោះ តុលាការមិនអាចលើកយកមកធ្វើការពិចារណាបានឡើយ ពីព្រោះចម្លើយជនត្រូវចោទឈ្មោះ[redacted]ដារ៉ុជ នៅមន្ត្រីនគរបាលយុត្តិធម៌ តំណាងអយ្យការចៅក្រមស៊ើបសួរ ជនជាប់ចោទ បានឆ្លើយសារភាពរួចរាល់អស់ហើយ ម្យ៉ាងវិញភស្តុតាងជាសារធាតុញៀនក៏បានធ្វើការដកហូតពីជនជាប់ចោទក្នុងពេលចុះបង្ក្រាបអាចជាបន្ទុកលើជនជាប់ចោទតាមច្បាប់។

-យល់ឃើញថាៈ មេធាវីការពារជនជាប់ចោទ បានស្នើសុំកែប្រែបទល្មើសពីបទ ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន មកជាបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន លើជនជាប់ចោទឈ្មោះ[redacted]រិទ្ធិ ដោយហេតុថា ក្នុងតំណាក់កាលចាប់ខ្លួនឈ្មោះ[redacted]រិទ្ធិ មិនមានឃើញឯកសារបញ្ជាក់ក្នុងការដកហូតវត្ថុតាងជាសារធាតុញៀនអ្វីនោះឡើយ ម្យ៉ាងវិញទៀតក្នុងតំណាក់កាលសួរតទល់ជាមួយឈ្មោះ[redacted] ដារ៉ុជ ឈ្មោះ[redacted]រិទ្ធិ ក៏បានបដិសេធដែរ គប្បីតុលាការពិនិត្យពិចារណា។

-យល់ឃើញថាៈ វត្ថុតាងដែលមានក្នុងកំណត់ហេតុលេខ៦២ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២១ គប្បីតុលាការសម្រេចរឹបអូស និងបំផ្លាញចោលតាមច្បាប់។

## ហេតុដូច្នេះសម្រេច

**១**/ ផ្តន្ទាទោសជនជាប់ចោទឈ្មោះ[redacted]ដារ៉ុជ ភេទប្រុស អាយុ ៤០ឆ្នាំ (មានសាវតាជាតិខាងលើ)

ដាក់ពន្ធនាគារកំណត់រយៈពេល ០២ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ពីបទៈ រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិមួយ ឃុំឡាមិញ ស្រុកបរកែវ ខេត្តរតនគិរី កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិផ្តន្ទាទោសតាមមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

Scanned with CamScanner

២/ ក- ឲ្យជនជាប់ចោទឈ្មោះ [redacted] រិទ្ធិ ភេទប្រុស អាយុ ៣១ឆ្នាំ (មានសាវតាជាតិខាងលើ) រួចផុតពីបទៈ រក្សាទុក និងដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិមួយ ឃុំឡាមិញ ស្រុកបរកែវ ខេត្តរតនគិរី កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិផ្តន្ទាទោសតាមមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ខ- ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] រិទ្ធិ ភេទប្រុស អាយុ ៣១ឆ្នាំ (មានសាវតាជាតិខាងលើ)

ដាក់ពន្ធនាគារកំណត់រយៈពេល ០៦ខែ គិតពីថ្ងៃឃុំខ្លួន ពីបទៈ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិមួយ ឃុំឡាមិញ ស្រុកបរកែវ ខេត្តរតនគិរី កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិផ្តន្ទាទោសតាមមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣/ វត្ថុតាងមានម្សៅក្រាមពណ៌សថ្លាសង្ស័យសារធាតុញៀន មានទម្ងន់ ៤,៨៤ ក្រាម, សម្ភារៈសេពគ្រឿងញៀន និងកាំភ្លើងកែច្នៃចំនួន ០១គ្រឿង ត្រូវរឹបអូសនិងបំផ្លាញចោល តាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៤/ ទូរស័ព្ទដៃម៉ាក OPPO ចំនួន ០១ គ្រឿង, ម៉ាក MT ចំនួន ០១ គ្រឿង, ម៉ូតូកែច្នៃចំនួន ០១ គ្រឿង និងម៉ូតូម៉ាកវេវ ពណ៌ខ្មៅ គ្មានផ្លាកលេខ ចំនួន ០១ គ្រឿង ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ។

៥/ សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ជាវុធ, ឈ្មោះ [redacted] រិទ្ធិ និងចំពោះមុខមេធាវីការពារជនជាប់ចោទ ។

*បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។*

**ក្រឡាបញ្ជីសវនាការ** [redacted]

**ចៅក្រមជំនុំជម្រះ** [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃចន្ទ ១១ កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រតនគិរី ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១
**ក្រឡាបញ្ជីសវនាការ**
[redacted]

បានឃើញ
**ចៅក្រមជំនុំជម្រះ**
[redacted]